# ឧបសម្ព័ន្ធ 1 ៖ ឯកសារដែលពាក់ព័ន្ធ

1.1-លិខិតស្នើសុំទីតាំង(មានការផ្លាស់ប្តូរទីតាំងចាស់មកទីតាំងថ្មី)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈរដ្ឋមន្ត្រី
ក្រសួងបរិស្ថាន

លេខ: ១០៧៨ ...កសណ...

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែឧសភា ឆ្នាំ ០៧

**សូមគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**កម្មវត្ថុ** : សំណើសុំអនុញ្ញាតជាគោលការណ៍ជូនក្រុមហ៊ុន អាល់ត្រា មីរ៉ន តិរ (ខេមបូឌា) រើកិលទីតាំងដីសម្បទាន សម្រាប់ធ្វើការសិក្សាស្រាវជ្រាវរុករករ៉ែពីតំបន់សែនចៅ ស្រុកសំឡូត ទៅទីតាំងថ្មី ដែលស្ថិតក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត ខេត្តបាត់ដំបង ។

<u>យោង</u>: លិខិតលេខ ០២/ ០៧ សណ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៧ របស់ក្រុមហ៊ុនអាល់ត្រា មីរ៉ន តិរ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមអនុញ្ញាតគោរពជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា: ក្រុមហ៊ុនអាល់ត្រា មីរ៉ន តិរ (ខេមបូឌា) បានចុះកិច្ចព្រមព្រៀង ស្តីពីការធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃនៅតំបន់សែនចៅ ស្ថិតក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០០០ ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលលើផ្ទៃដីសម្បទានសរុប ០៤គម២ ។ ក្រោយពីបានធ្វើការសិក្សាស្វែងយល់ និងធ្វើតេស្តសាកល្បងកន្លងមក ក្រុមហ៊ុនបានវាយតម្លៃថា ទីតាំងនោះពុំមានសក្តានុពលអាចធ្វើអាជីវកម្មរ៉ែត្បូងថ្មបានទេ ហេតុនេះ ក្រុមហ៊ុនបានស្នើសុំរើកិលទីតាំងដីសម្បទានពីតំបន់សែនចៅនេះ ទៅកាន់ទីតាំងថ្មី ដែលមានទំហំផ្ទៃដី ០៤គម២ ដដែល និងមានទិសកាដូចខាងក្រោម:

| | | |
|---|---|---|
| A: 0243000E-1397000N | B: 0243500E-1397000N | C: 0243500E-1397500N |
| D: 0245000E-1397500N | E: 0245000E-1398000N | F: 0247000E-1398000N |
| G: 0247000E-1397500N | H: 0246500E-1397500N | I: 0246500E-1397000N |
| J : 0245500E-1397000N | K: 0245500E-1396500N | L: 0244500E-1396500N |
| M:0244500E-1396000N | N: 0244000E-1396000N | O: 0244000E-1396500N |
| P: 0243000E-13965000N | | |

ខ្ញុំបាទសូមគោរពអនុញ្ញាតជម្រាបជូនសម្តេចមេត្តាជ្រាបថា ដើម្បីឱ្យការវិនិយោគធានាបាននូវនិរន្តរភាពបរិស្ថានធម្មជាតិ និងស្តារឡើងវិញនូវជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ ដែលត្រូវបានធ្វើការសិក្សាស្រាវជ្រាវ ស្វែងយល់ និងធ្វើតេស្តសាកល្បង ដោយការជីកកកាយជារណ្តៅរួចហើយនោះ ជាយោបល់របស់ក្រសួងបរិស្ថានសំណូមពរសុំ:

១- ក្រុមហ៊ុនធ្វើការចូលលុប រណ្តៅដែលបានជីកកាយរួច និងធ្វើការដាំដើមឈើឡើងវិញ ព្រមទាំងធ្វើការសំអាតបរិស្ថាននៅតំបន់ធ្វើអាជីវកម្មនោះឱ្យបានរួចរាល់នៅលើទីតាំងចាស់កន្លងមក ។



ផ្ទះលេខ៩៩IB. ផ្លូវលេខ២៣០. សង្កាត់ទឹកល្អក់៣. ខណ្ឌទួលគោក. រាជធានីភ្នំពេញ. ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 210 313. ទូរសារ : (855) 23 214 070. អ៊ីម៉ែល : info@ces.com.kh. គេហទំព័រ : www.ces.com.kh

២- មុននឹងធ្វើការស្រាវជ្រាវរុករករ៉ែជាបន្តទៀតនោះ ក្រុមហ៊ុនត្រូវរៀបចំប្លង់មេឱ្យបានច្បាស់លាស់ ។

៣- ក្រុមហ៊ុនត្រូវរៀបចំធ្វើផែនការគ្រប់គ្រង និងធ្វើកិច្ចសន្យាការពារបរិស្ថានជូនក្រសួងបរិស្ថាន ដើម្បីចូលរួមកាត់បន្ថយនូវហេតុប៉ះពាល់ដល់បរិស្ថានធម្មជាតិ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូមសម្តេចនាយករដ្ឋមន្ត្រីមេត្តាពិនិត្យ និងសុំមតិសម្រេចដោយក្តីអនុគ្រោះ ។

សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

1.2-អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតំលៃ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ១០៣៨ ឧរថ.ធរ.អប.

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០៧

## អាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញកិច្ចព្រមព្រៀងវិនិយោគទុនរ៉ែ នៅតំបន់ សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង ចុះថ្ងៃ ទី ២៨ ខែមិថុនា ឆ្នាំ ២០០០ ។
- បានឃើញសេចក្តីកែតម្រូវលេខ ០០១ នៃកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ នៅតំបន់សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០០៤ ។
- បានឃើញអាជ្ញាប័ណ្ណធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតំលៃលេខ ៧៨៤ ឧរថ.ធរ.អប. ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ។
- បានឃើញលិខិតស្នើរកិលទីតាំងរបស់ក្រុមហ៊ុន លេខ ០៧/០៦ ស.ណ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០០៦ ។
- បានឃើញសេចក្តីកែតម្រូវលេខ ០០២ នៃកិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ នៅតំបន់សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង ចុះថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៧ ។

## សម្រេច

**ប្រការ១** : អនុញ្ញាតិអោយក្រុមហ៊ុន ULTRA MARINE KIRI (CAMBODIA) CO., LTD មានអាសយដ្ឋានផ្ទះលេខ ១៧ក ក្រុម១ ភូមិមិត្តភាព សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ធ្វើអាជីវកម្មរ៉ែត្បូងថ្មមានតម្លៃ នៅតំបន់សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង លើផ្ទៃដីទំហំ ០៤(បួន) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥) ២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh, Phone: (855) 23 211 141 Fax: (855) 23 428 263

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | $2\,43^{000}$ | $13\,97^{000}$ | I | $2\,46^{500}$ | $13\,97^{000}$ |
| B | $2\,43^{500}$ | $13\,97^{000}$ | J | $2\,45^{500}$ | $13\,97^{000}$ |
| C | $2\,43^{500}$ | $13\,97^{500}$ | K | $2\,45^{500}$ | $13\,96^{500}$ |
| D | $2\,45^{000}$ | $13\,97^{500}$ | L | $2\,44^{500}$ | $13\,96^{500}$ |
| E | $2\,45^{000}$ | $13\,98^{000}$ | M | $2\,44^{500}$ | $13\,96^{000}$ |
| F | $2\,47^{000}$ | $13\,98^{000}$ | N | $2\,44^{000}$ | $13\,96^{000}$ |
| G | $2\,47^{000}$ | $13\,97^{500}$ | O | $2\,44^{000}$ | $13\,96^{500}$ |
| H | $2\,46^{500}$ | $13\,97^{500}$ | P | $2\,43^{000}$ | $13\,96^{500}$ |

<u>ប្រការ២</u> : ក្នុងដំណើរការអាជីវកម្មរ៉ែត្បូងថ្មនៅតំបន់ដូចមានចែងក្នុងប្រការ១ខាងលើ ក្រុមហ៊ុនត្រូវទទួលយកមន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងប្រការ ១៦.១ នៃកិច្ចព្រមព្រៀងវិនិយោគទុនរ៉ែ នៅតំបន់សែនចៅ ស្រុកសំឡូត ខេត្តបាត់ដំបង ចុះថ្ងៃ ទី ២៨ ខែមិថុនា ឆ្នាំ ២០០០ អោយចូលរួមគ្រប់សកម្មភាពប្រតិបត្តិការធនធានរ៉ែ និង ត្រូវអនុវត្តទៅតាមគោលការណ៍បច្ចេកទេសអាជីវកម្មធនធានរ៉ែ និង លក្ខខ័ណ្ឌដែលមានចែងលំអិតនៅក្នុងកិច្ចព្រមព្រៀង ។

<u>ប្រការ៣</u> : អាជ្ញាប័ណ្ណនេះមានតំលៃរយៈពេល០២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណអាជីវកម្មរ៉ែត្បូងថ្មបន្តជាថ្មី អោយបាន ៦០ (ហុកសិប) ថ្ងៃ មុនអាជ្ញាប័ណ្ណនេះអស់សុពលភាព ។

<u>ប្រការ៤</u> : ក្នុងករណីជួបប្រទះរ៉ែផ្សេងទៀតក្រៅពីត្បូងថ្ម ក្រុមហ៊ុនត្រូវរាយការណ៍មកក្រសួងជាបន្ទាន់ ។ ក្នុងករណីប្រព្រឹត្តិល្មើស អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូតដោយគ្មានលក្ខខ័ណ្ឌ ។

<u>ប្រការ៥</u> : អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តបាត់ដំបង និង ប្រធានក្រុមហ៊ុន ULTRA MARINE KIRI (CAMBODIA) CO., LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារកិច្ចរៀងៗខ្លួន ។

<u>ប្រការ៦</u> : អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ស៊ុយ_សែម

<u>ចំលងជូន</u>

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងធនធានទឹក និង ឧតុនិយម
- សាលាខេត្តបាត់ដំបង
- សាលាស្រុកសំឡូត

(ដើម្បីជ្រាបជាព័ត៌មាន)

- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

1.3-លិខិតចុះសិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
Ministry of Environment

លេខ: ០១៧ សស៧.ប.ស្ល

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១០

**ជំរាបមក**

**លោកនាយកក្រុមហ៊ុន** CES CO., LTD.

**កម្មវត្ថុ:**ករណីសំណើសុំការអនុញ្ញាតចុះសិក្សាស្រាវជ្រាវវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង លើគំរោងអាជីវកម្មរ៉ែត្បូងថ្មមានតំលៃ របស់ក្រុមហ៊ុន ULTRA MARINE KIRI (CAMBODIA) CO., LTD. ។

**យោង:** លិខិតលេខ EC០៩១២០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រុមហ៊ុន CES CO., LTD ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនលោកនាយកក្រុមហ៊ុនជ្រាបថា: ក្រសួងបរិស្ថានឯកភាពលើសំណើចុះសិក្សាស្រាវជ្រាវវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង លើគំរោងអាជីវកម្មរ៉ែត្បូងថ្មមានតំលៃ ដែលមានទីតាំងស្ថិតនៅតំបន់សែនពៅ ស្រុកសំឡូត ខេត្តបាត់ដំបង របស់ក្រុមហ៊ុន ULTRA MARINE KIRI (CAMBODIA) CO., LTD. ដើម្បីរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០១០ ដែលមានសមាសភាពចុះទៅសិក្សាដូចខាងក្រោម:

| | |
|---|---|
| ១- លោក សុខ សុជា | ៤-អ្នកស្រី ឡុច វណ្ណៈ |
| ២- លោក ឯម ចំណាប់ | ៥-លោក និត សុផា |
| ៣- លោក កាក់ សុគាន | ៦-ក្រុមអ្នកសិក្សា និងឧបករណ៍ផ្សេងៗ ។ |

ក្រុមហ៊ុនត្រូវធ្វើការទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នជំនាញពាក់ព័ន្ធនៅក្នុងតំបន់នោះ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកនាយកជ្រាបតាមការគួរ និងទទួលនូវការរាប់អានអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

ម៉ុក ម៉ារ៉េត

ចំលងជូន
- អគ្គនាយកដ្ឋានបច្ចេកទេស នៃក្រសួងបរិស្ថាន
- នាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងបរិស្ថាន
- សាលាខេត្តបាត់ដំបង
- មន្ទីរបរិស្ថានខេត្តបាត់ដំបង
- ឯកសារ-កាលប្បវត្តិ